# តំបន់វប្បធម៌សេន អាហ្គូស្ទីន

សេន អាហ្គូស្ទីន (San Agustin) មានទីតាំងស្ថិតនៅខាងត្បូងនៃជួរភ្នំ អង់ដេស(Andes) និងស្ថិតនៅតំបន់ផ្នែកខាងលើនៃទន្លេ Magdalena ក្នុងខេត្ត ហ៊ូឡា (Huila) ប្រទេសកូឡុំប៊ី ។ តំបន់នៃស្ថានីយនេះ គឺមានវិសាលភាពទឹកដីធំធេងដែលផ្ទៃដីខាងលិចចាប់ពី តំបន់ព្រៃទឹកភ្លៀង Chocoan រហូតដល់សមុទ្រប៉ាស៊ីហ្វិច។[១]

លើសពីនេះសេន អាហ្គូស្ទីន គឺជាទីតាំងនៃសាសនាដ៏ធំរបស់ប្រជាជនបុរាណក្នុងតំបន់ទ្វីបអាមេរិកខាងត្បូង ក្នុងចំណោមបណ្ដាវប្បធម៌ដទៃទៀតក្នុងទ្វីបអាមេរិកដូចជា ធារិន, អូមិច, មីយ៉ា ជាដើម។[២] ស្ថានីយបុរាណវិទ្យាមួយនេះក៏បានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកក្នុងឆ្នាំ១៩៩៥ (រូបលេខ១)។

ការធ្វើការស្រាវជ្រាក្នុងតំបន់ សេន អាហ្គូស្ទីនបានចាប់ផ្ដើមឡើងដំបូងក្នុងឆ្នាំ១៩៦០ រហូតដល់ឆ្នាំ ១៩៧៥ ដែលក្នុងអំឡុងពេលនោះ ការស្រាវជ្រាវសំខាន់ៗ គឺជួសជុល និងរៀបចំសំណង់ក្នុងស្ថានីយសេន អាហ្គូស្ទីនឡើងវិញ ដោយសារសំណង់ភាគច្រើនត្រូវបានចោរលួច គាស់កកាយ បំផ្លាញ។ នៅឆ្នាំ១៩៦៤ អ្នកបុរាណវិទូជនជាតិកូឡុំប៊ីម្នាក់ឈ្មោះ Duque Gómez បានបោះពុម្ពសៀវភៅអំពីការធ្វើការស្រាវជ្រាវនៅក្នុងតំបន់នេះ ដោយលោកក៏បានបង្ហាញអំពីកាលបរិច្ឆេទនៃស្ថានីយនេះដែលមានស្រទាប់ដីចាស់ជាងគេក្នុងឆ្នាំ៣៣០០មុនគ.ស.។[៣] គួរបញ្ជាក់ដែរថាតំបន់នេះក៏ជាបណ្ដុំនៃសំណង់សាសនាដ៏ធំក្នុងទ្វីបអាមេរិកខាងត្បូងដែលមានរូបរាងរហូតដល់សព្វថ្ងៃនេះ។[៤]

សំណង់នៅក្នុងស្ថានីយបុរាណវិទ្យាសេន អាហ្គូស្ទីនគឺជាបណ្ដុំនៃសំណង់ស្ថាបត្យកម្មបែបសាសនា ដូចជា សំណង់សម្រាប់បញ្ចុះសព ប្រាសាទ និង ទីតាំងសំណង់សាសនា

---

[១] Velandia 1999, p. 185.

[២] Ibid

[៣] Velandia 1999, p. 186.

[៤] San Agustín Archaeological Park - UNESCO World Heritage Centre

អត្ថបទដោយ៖ អេង តុលា

ផ្សេងៗទៀត ដែលកសាងជាពន្នកដីនិងមានថ្មៗ បច្ចុប្បន្នស្ថានីយនេះមានផ្ទៃដី១១៦ហិតា ដែលបែងចែកជាបីតំបន់គឺ Mesita A, Mesita B, Mesita Cៗ[៥] ទីតាំងនៃសំណង់ទាំងនោះគឺស្ថិតនៅក្បែរៗគ្នា មានគម្លៀតពីមួយទៅមួយប្រមាណជាង៣០ម និងមានផ្លូវធំមួយនៅខាងមុខៗ ចំពោះសំណង់ផ្នូរដែលកសាងអំពីថ្មធំ កសាងនៅក្នុងសម័យកាលដំបូង(១ដល់៩០០នៃគ.ស.) ដែលសម្រាប់មេដឹកនាំធំក្នុងសម័យកាលនោះៗ

តាមរយៈសំណង់ស្ថាបត្យកម្មទាំងនោះ ទីតាំងនៃស្ថានីយនេះគឺជាទីក្រុងនៃសាសនាដ៏ធំរបស់មនុស្សសម័យបុរាណក្នុងប្រទេសកូឡុំប៊ី និងក្នុងទ្វីបអាមេរិកខាងត្បូងផងដែរៗ រូបចម្លាក់ដែលឃើញមាននៅទីនេះគឺស្រដៀងទៅនឹងរូបនៅតំបន់ភ្នំអង់ដេស ខាងជើង ដែលស្ថិតនៅក្នុងទ្វីបអាមេរិកកណ្ដាលៗ សិល្បៈសំណង់ស្ថាបត្យកម្មក្នុងស្ថានីយ សេន អាហ្គូស្ទីន គឺមានភាពប្លែក និងមានតែមួយ ដែលបានបង្ហាញអំពីបច្ចេកទេស និងគំនិតច្នៃប្រឌិតអំពីការកសាងផ្នូរ និងការឆ្លាក់រូបចម្លាក់សម្រាប់ឧទ្ទិសដល់ទេព(រូបលេខ២-៣)ៗ[៦]

តាមរយៈទីតាំងភូមិសាស្ត្រ អ្នកស្រាវជ្រាវលើកឡើងថា ប្រជាជនក្នុងតំបន់នេះរស់នៅក្នុងព្រៃទ្រូពិកដែលពឹងលើការបរបាញ់សត្វ ព្រៃ និងនេសាទ ៗ ក្រៅពីនេះ តំបន់នៃស្ថានីយនេះត្រូវបានបោះបង់ចោលប្រហែលនៅឆ្នាំ១៣៥០នៃគ.ស. និងមានការមកតាំងទីវិញនៅស.វ.ទី ១៨ និង ១៩នៃគ.ស.ៗ[៧] ការសន្និដ្ឋានដោយអ្នកស្រាវជ្រាវបុរាណវិទ្យាការបោះបង់ចោលនោះ គឺប្រហែលមកពីកត្តាធម្មជាតិដែលមានការរញ្ជួយដី និងប្រហែលពីការឈ្លានពានពីអរិយធម៌ផ្សេងនៅក្នុងទ្វីបអាមេរិកជាពិសេស អេស្បាញ និងព័រទុលហ្គាលៗ ក្រុមអ្នកស្រាវជ្រាវបានបន្តការងារជួសជុលរូបចម្លាក់ និងជួសជុលផ្នូរនៅក្នុងទីតាំងនោះ ដើម្បីបើកបង្ហាញសាធារណៈជនឲ្យបានចូលទស្សនាផងដែរ៕

[៥] San Agustín Archaeological Park - UNESCO World Heritage Centre

[៦] Unesco p. 14.

[៧] San Agustín Archaeological Park - UNESCO World Heritage Centre

អត្ថបទដោយ៖ អេង តុលា



រូបលេខ១៖ ផែនទីនៃស្ថានីយសេន អាហ្គូស្ទីន និងរូបលេខ២៖ ទីតាំងនៃសំណង់ក្នុងស្ថានីយ
ប្រភព៖ UNESCO



ស៍ តុលា



រូបលេខ៣-៤៖ រូបចម្លាក់ទេព

ប្រភព៖ UNESCO



## ឯកសារយោង

César Velandia

1999 The archaeological culture of San Agustín. (PDF) The archaeological culture of San Agustín. Towards a new interpretation (researchgate.net)

San Agustín Archaeological Park - UNESCO World Heritage Centre

អត្ថបទដោយ៖ អេង តុលា